# ផ្នែកទី ១ ៖ ជីវសុវត្ថិភាពកម្រិតមូលដ្ឋាន

## ១.២. សេចក្ដីផ្ដើមអំពីការគ្រប់គ្រងជីវហានិភ័យ

# នៅចុងបញ្ចប់នៃម៉ូឌុលសិក្សានេះ
# អ្នកគួរតែមានសមត្ថភាពអាច៖

- ដឹងអំពីទស្សនាទានជាមូលដ្ឋាន និងពាក្យបច្ចេកទេសនៃការគ្រប់គ្រងជីវហានិភ័យ
- យល់អំពីគំរូ AMP សម្រាប់ការគ្រប់គ្រងជីវហានិភ័យ
- យល់អំពីអត្ថប្រយោជន៍នៃការអនុវត្តប្រព័ន្ធការគ្រប់គ្រងជីវហានិភ័យ ដើម្បីកាត់បន្ថយហានិភ័យពាក់ព័ន្ធជាមួយការចាត់ចែង ការស្តុកទុក និងការបោះចោលភ្នាក់ងារជីវសាស្ត្រ
- យល់អំពីតួនាទីរៀងខ្លួនរបស់អ្នកប្រតិបត្តិនានាដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងជីវហានិភ័យ

# ទិដ្ឋភាពទូទៅ

- ពិនិត្យឡើងវិញលើទស្សនៈនានាទានមូលដ្ឋាន និងស័ព្ទបច្ចេកទេសទាក់ទងជាមួយការគ្រប់គ្រងជីវហានិភ័យ
- គោលបំណង និងឥទ្ធិពលនៃកត្តាពាក់ព័ន្ធ ដូចជា ភ្នាក់ងារជីវសាស្ត្រ ភ្នាក់ងារផ្ទុក បរិស្ថាន និងការងារមន្ទីរពិសោធន៍នៅក្នុងការគ្រប់គ្រងជីវហានិភ័យ
- ណែនាំឲ្យស្គាល់អំពីគំរូ AMP (ការវាយតម្លៃ ការកាត់បន្ថយ និងការអនុវត្ត )
- ឧបករណ៍ និងធនធាន ដើម្បីអនុវត្តប្រព័ន្ធគ្រប់គ្រងជីវហានិភ័យ
- ពិពណ៌នាអំពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកដើរតួនានា ដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងជីវហានិភ័យ

# លំហាត់ជាក្រុម

## លំហាត់ទី ១

សូមចែកទៅជាក្រុមតូចៗ៖

ពិភាក្សា និង ឆ្លើយសំនួរខាងក្រោមជាក្រុមក្នុងរយៈពេល ១០នាទី ៖
តើក្នុងការធ្វើការជាមួយវត្ថុធាតុជីវសាស្ត្រ នៅក្នុងមន្ទីរពិសោធន៍មានហានិភ័យអ្វីខ្លះ?

សូមផ្តល់ចម្លើយរបស់អ្នកទៅអ្នកដែលចូលរួមក្នុងវគ្គសិក្សានេះវិញ

# និយមន័យ

**ជីវសុវត្ថិភាពមន្ទីរពិសោធន៍**[1]៖ គោលការណ៍ទប់ស្កាត់ និង បច្ចេកវិទ្យា ព្រមទាំងការដាក់ឲ្យអនុវត្ត ដើម្បីបង្ការ ការសាយភាយ និងការប្រឈមចំពោះភ្នាក់ងារបង្ករោគនិង Toxins ដោយចៃដន្យ ។

**ជីវសន្តិសុខមន្ទីរពិសោធន៍**[2]៖ ការការពារ ការគ្រប់គ្រង និងគណនេយ្យភាពចំពោះវត្ថុធាតុជីវសាស្ត្រមានតម្លៃនៅក្នុងមន្ទីរពិសោធន៍ ដើម្បីទប់ស្កាត់កុំឲ្យ អ្នកគ្មានការអនុញ្ញាត អាចចូលទៅកន្លែងទុកដាក់វត្ថុធាតុជីវសាស្ត្រទាំងនោះ និងដើម្បីទប់ស្កាត់កុំអោយមានការបាត់បង់ ការលួច ការប្រើប្រាស់ខុសបច្ចេកទេស ការបង្វែរ ឬការបញ្ចេញទៅក្រៅដោយចេតនា







1*Laboratory biosafety manual, Third edition* (WHO, 2004)
2*Biorisk management Laboratory biosecurity guidance* (WHO, 2006)

# ការគ្រប់គ្រងជីវហានិភ័យមន្ទីរពិសោធន៍

ប្រព័ន្ធ ឬដំណើរការដើម្បីគ្រប់គ្រងសុវត្ថិភាព និងសន្តិសុខ នៃហានិភ័យពាក់ព័ន្ធជាមួយការចាត់ចែង ឬការទុកដាក់ និងការបោះបោលភ្នាក់ងារជីវសាស្ត្រ និងToxins នៅក្នុងមន្ទីរពិសោធន៍ និងក្នុងគ្រឹះស្ថាន

CWA 15793:2011


CEN
WORKSHOP
AGREEMENT

CWA 15793

Laboratory biorisk management

# ជីវហានិភ័យ

- ហានិភ័យដែលពាក់ព័ន្ធជាមួយវត្ថុធាតុជីវសាស្រ្តនៅក្នុងមន្ទីរពិសោធន៍ ដែលមានសមាសធាតុពាក់ព័ន្ធជាមួយសុវត្ថិភាព និងសន្តិសុខ

- ជីវហានិភ័យ គ្របដណ្តប់លើហានិភ័យដែលចេញពីទស្សនៈវិស័យផ្នែកជីវសុវត្ថិភាព និងជីវសន្តិសុខរបស់មន្ទីរពិសោធន៍ពាក់ព័ន្ធជាមួយវត្ថុធាតុជីវសាស្រ្ត

# លំហាត់ជាក្រុម

## លំហាត់ទី ២

សូមធ្វើការងារនៅក្នុងក្រុមរបស់អ្នក ដោយចំណាយពេល ១០ នាទី ដើម្បីពិភាក្សា និងឆ្លើយតបសំណួរទាំងបីខាងក្រោម៖

- តើធ្វើយ៉ាងណា ទើបអ្នកអាចកំណត់អត្តសញ្ញាណហានិភ័យទាំងអស់នេះបាន?
- តើជំហានណាខ្លះដែលអ្នកត្រូវធ្វើ ដើម្បីគ្រប់គ្រងលើហានិភ័យទាំងអស់នេះ?
- តើធ្វើយ៉ាងណា ទើបអ្នកអាចដឹងថា ការគ្រប់គ្រងហានិភ័យរបស់អ្នកដំណើរការបានល្អ ហើយនឹងបន្តដំណើរការបានល្អ?

សូមប្រើប្រាស់ក្រដាសស្អិត(Post it) ដើម្បីសរសេរចម្លើយរបស់អ្នក ដោយប្រើក្រដាសស្អិតមួយសម្រាប់គំនិតមួយ រួចបិទក្រដាសស្អិតនោះនៅលើក្រដាសផ្ទាំងធំ

សូមផ្តល់ចម្លើយរបស់អ្នក ទៅអ្នកដែលចូលរួមក្នុងវគ្គសិក្សានេះទាំងអស់

# លំហាត់ជាក្រុម

## លំហាត់ទី 3

ឥឡូវនេះសូមដាក់គំនិតទាំងនេះទៅតាមចំណាត់ប្រភេទនីមួយៗ៖

សូមយកក្រដាសស្អិតទៅបិទលើក្រដាសនៅក្រោមជួរបញ្ឈរណាមួយនៅក្នុងចំណោមជួរបញ្ឈរខាងក្រោម៖

| ការវាយតម្លៃ | ការកាត់បន្ថយ | ការអនុវត្ត |
| --- | --- | --- |
| | | |

# សមាសធាតុសំខាន់ៗនៃការគ្រប់គ្រងជីវហានិភ័យ

- ការវាយតម្លៃជីវហានិភ័យ
- ការកាត់បន្ថយជីវហានិភ័យ
- ការអនុវត្ត



# ការគ្រប់គ្រងជីវហានិភ័យ

## គំរូ AMP

ការគ្រប់គ្រងជីវហានិភ័យ =

(ការវាយតម្លៃ, ការកាត់បន្ថយ, ការអនុវត្ត)

Assessment, Mitigation, Performance

# សមាសធាតុសំខាន់ៗនៅក្នុងការគ្រប់គ្រងជីវហានិភ័យ

ក្នុងវគ្គបន្ទាប់ទៀត យើងនឹងត្រឡប់មកមើលគំរូ AMP វិញ ហើយឆ្លើយទៅនឹងសមាសធាតុទាំងបីនេះម្តងមួយៗ

ការគ្រប់គ្រងជីវហានិភ័យ =

(ការវាយតម្លៃ, ការកាត់បន្ថយ, ការអនុវត្ត)

Assessment, Mitigation, Performance

# ការវាយតម្លៃជីវហានិភ័យ

# លំហាត់ជាក្រុម (លំហាត់ទី ៤)

សូមពិចារណាលើសេណារីយ៉ូខាងក្រោម៖

កុមារអាយុពីរឆ្នាំម្នាក់ ត្រូវបានទុកចោលឲ្យនៅម្នាក់ឯងក្នុងផ្ទះបាយពេលកំពុងមានទឹកដាំពុះនៅលើចង្ក្រាន។

សូមចំណាយពេល ១០ នាទី ដើម្បីឆ្លើយនឹងសំណួរខាងក្រោម៖

តើមានរឿងអាក្រក់អ្វីអាចកើតឡើង? សូមរៀបរាប់លទ្ធភាពដែលអាចកើតមានទាំងអស់

សូមជ្រើសរើសហានិភ័យណាមួយដែលសំខាន់ជាងគេបំផុត សម្រាប់ សេណារីយ៉ូនេះ និងកំណត់រកភាពគ្រោះថ្នាក់សម្រាប់ហានិភ័យនោះ

សូមប្រាប់ទៅអ្នកចូលរួមក្នុងថ្នាក់ទាំងមូលវិញ

# តើអ្វីជាគ្រោះថ្នាក់?

- គ្រោះថ្នាក់ គឺជាប្រភព ឬវត្ថុធាតុដែលអាចបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានកើតឡើង

- **គ្រោះថ្នាក់** ពុំទាន់ជាហានិភ័យទេ ប្រសិនបើគ្មាន បរិស្ថាន ឬស្ថានភាពជាក់លាក់

តើអ្វីដែលជះឥទ្ធិពលធ្វើឲ្យឧបទ្ទវហេតុមួយ ដែលអាចកើតមាន ឬមិនអាចកើតមាន? តើឧបទ្ទវហេតុនោះទំនងជាកើតមានកម្រិតណា?

តើឧបទ្ទវហេតុនោះ អាចមានភាពធ្ងន់ធ្ងរកម្រិតណា?

តើអ្វីដែលជះឥទ្ធិពលលើវិបាកនៃឧបទ្ទវហេតុនោះ?

តើអ្វីជា ហានិភ័យ?

# តើអ្វីជា ហានិភ័យ?

ហានិភ័យ គឺជាភវនិយភាព (ភាពទំនងជាអាចកើតមាន) នៃព្រឹត្តិការណ៍មួយ ដោយមានគ្រោះថ្នាក់ដែលបង្កឲ្យមានផលវិបាក



# តើអ្វីជា ហានិភ័យ?

ពេលវេលា

ឧបទ្ទវហេតុ

## ភវនីយភាព

កត្តានានាដែលជះឥទ្ធិពល ធ្វើឲ្យឧបទ្ទវហេតុនោះអាចកើតមាន ឬមិនអាចកើតមាន

## ផលវិបាក

កត្តានានាដែលជះឥទ្ធិពល លើភាពធ្ងន់ធ្ងរនៃឧបទ្ទវហេតុ

# លំហាត់ជាក្រុម (លំហាត់ទី ៥)

សូមពិចារណាជាថ្មីម្តងទៀតលើសេណារីយ៉ូ អំពីក្មេងអាយុពីរឆ្នាំនៅក្នុងផ្ទះបាយ៖

**ហានិភ័យ៖ ក្មេងនោះត្រូវរលាក ដោយទឹកកំពុងពុះ**

**ប្រភពគ្រោះថ្នាក់៖ ឆ្នាំងទឹកដាំពុះនៅលើចង្ក្រាន**

សូមចំណាយពេល ១៥ នាទី ដើម្បី៖

- កំណត់រកគ្នានានា ដែលជះឥទ្ធិពលលើ ភាពទំនងអាចកើតមាន និងផលវិបាកនៃហានិភ័យ សូមប្រើក្រដាសស្អិតសម្រាប់សរសេរកត្តានីមួយៗ
- វាយតម្លៃលើហានិភ័យ (ទាប មធ្យម ខ្ពស់)
- សូមប្រាប់ទៅអ្នកចូលរួមក្នុងថ្នាក់ទាំងមូលវិញ

តើអាចមានភាពខុសគ្នាអ្វីខ្លះ ប្រសិនបើហានិភ័យនោះគឺ កុមារអាយុពីរឆ្នាំត្រូវរងរបួសដោយសារបងប្រុសរបស់ខ្លួនវាយ ដោយសារក្មេងអាយុពីរឆ្នាំនោះធ្វើឲ្យខូចប្រដាប់លេងរបស់គេ?

តើអ្វីជា(ការគម្រាមកំហែង)គ្រោះថ្នាក់នៅពេលនេះ ?

តើអ្វីជាភាពខុសគ្នារវាង**គ្រោះថ្នាក់** និង **ការគម្រាមកំហែង**?

# គ្រោះថ្នាក់ ការគម្រាមកំហែង និង ហានិភ័យ

- **គ្រោះថ្នាក់** គឺជាអំពើ ឬវត្ថុធាតុដែលអាចបង្កអោយមានផលប៉ះពាល់ជាអវិជ្ជមាន
- ក្នុងន័យ សន្តិសុខ **ការគម្រាមកំហែង** គឺពាក់ព័ន្ធជាមួយជនណាម្នាក់ដែលមានចេតនាបង្កគ្រោះថ្នាក់ដល់ជនដទៃ សត្វ ឬស្ថាប័ននានា
- **ហានិភ័យ** អាចជាគ្រោះថ្នាក់ ឬគ្រោះថ្នាក់ បូករួមជាមួយការគម្រាមកំហែង

តើយើងអាចកំណត់និយមន័យ ហានិភ័យ ភាវនីយភាព (ភាពទំនងដែលអាចកើតមាន) និងផលវិបាក បានយ៉ាងដូចម្តេច?

# ហានិភ័យ ភវនីយភាព(Likelihood) និងផលវិបាក

**ហានិភ័យ** គឺជាភាពដែលអាចកើតមាននៃហេតុការណ៍គ្រោះថ្នាក់ណាមួយ(ឬគ្រោះថ្នាក់ និងការកម្រាម) ដែលបង្កឲ្យមានផលវិបាក

**ភវនីយភាព (likelihood)** គឺជាលទ្ធភាពដែលអាចកើតមាន នៃហេតុការណ៍ណាមួយ

**ផលវិបាក** គឺជាកំរិតធ្ងន់ធ្ងរនៃហេតុការណ៍

# តើយើងអាចកំណត់ហានិភ័យជាលក្ខណៈសមីការបានដោយរបៀបណា?

$$R = f(L, C)$$

# ក្រាហ្វិចហានិភ័យទី ១



# ក្រាហ្វិចហានិភ័យទី ២

បរិមាណទឹកពុះច្រើននៅលើចង្ក្រាន

មានកៅអីជាន់ឡើងនៅជាប់ចង្ក្រាន

ពុំមានអ្វីរារាំងទប់ស្កាត់កុមារ



# ក្រាហ្វិចហានិភ័យទី ៣

ទឹកកំពុងពុះបរិមាណច្រើន

ពុំមានកៅអីជាន់ឡើង

កុមារត្រូវបានដាក់ខ្សែក្រវាត់

ជាប់នៅលើកៅអីខ្ពស់



# គ្រោះថ្នាក់ទី ៤

ទឹកត្រជាក់បរិមាណតិចតួចនៅក្នុងឆ្នាំងខ្ទះដែលដាក់លើចង្ក្រានក្ដៅ

មានកៅអីជាន់ឡើងនៅជាប់ចង្ក្រាន

ពុំមានអ្វីរារាំងទប់ស្កាត់កុមារ



# ក្រាហ្វិចហានិភ័យទី ៥

ទឹកត្រជាក់បរិមាណតិចតួចនៅលើចង្ក្រានក្តៅ

ពុំមានកៅអីជាន់ឡើង

កុមារត្រូវបានដាក់ខ្សែក្រវាត់

ជាប់នៅលើកៅអីខ្ពស់



# ការឆ្លុះបញ្ចាំងជាលក្ខណៈបុគ្គល

- តើអ្នកធ្វើការវាយតម្លៃហានិភ័យនៅក្នុងមន្ទីរពិសោធន៍របស់អ្នកដោយរបៀបណា?
- សូមសរសេរចម្លើយរបស់អ្នក រួចចែករំលែកជាមួយអ្នកផ្សេងទៀតនៅតុរបស់អ្នក
- ប្រសិនបើអ្នកចង់ អ្នកអាចចែករំលែកគំនិតរបស់អ្នកជាមួយអ្នកដទៃទៀតនៅក្នុងថ្នាក់

# លំហាត់ជាក្រុម

## លំហាត់ទី ៧

សូមពិចារណាលើសេណារីយ៉ូជីវសាស្ត្រទី ១ (HIV)៖

ចំណាយពេល១៥ នាទី ដើម្បី៖



កំណត់រកហានិភ័យនៅក្នុងសេណារីយ៉ូនេះ

សូមប្រាប់ទៅអ្នកចូលរួមក្នុងថ្នាក់ទាំងមូលវិញ



តើអ្នកផ្តោតការយកចិត្តទុកដាក់លើទិដ្ឋភាពអ្វីនៃជីវហានិភ័យ?

# លំហាត់ជាក្រុម (លំហាត់ទី ៧)

សូមត្រលប់ទៅសេណារីយ៉ូស្តីពីជំងឺអេដស៍វិញ៖



ចំណាយពេល ៥ នាទី ដើម្បី៖



- ជ្រើសរើសហានិភ័យមួយ ដើម្បីវាយតម្លៃ
- កំណត់និយមន័យគ្រោះថ្នាក់ និង/ឬការគម្រាមកំហែង
- តើអ្នកអាចវាយតម្លៃហានិភ័យរបស់សេណារីយ៉ូនេះ ឬទេ? ប្រសិនបើអាច តើអ្វីជាហានិភ័យ (ទាប/មធ្យម/ខ្ពស់)?

សរសេរចម្លើយដាក់លើក្រដាសផ្ទាំងធំ និងរាយការណ៍ជូនថ្នាក់ទាំងមូលវិញ

# លំហាត់ជាក្រុម (លំហាត់ទី ៨)



សូមប្រើសេណារីយ៉ូស្តីពីជំងឺអេដស៍ឡើងវិញ

ចំណាយពេល ២០ នាទី ដើម្បីឆ្លើយនឹងសំណួរខាងក្រោមៈ

តើព័ត៌មានប្រភេទអ្វីខ្លះដែលអ្នកត្រូវការ ដើម្បីធ្វើការវាយតម្លៃហានិភ័យ?

សូមសរសេរសំណួរទាំងអស់ដែលអ្នកគិតថាចាំបាច់ត្រូវលើកមកសួរ

សូមប្រើប្រាស់ក្រដាសស្អិតតូចៗ ដើម្បីសរសេរមួយសំណួរក្នុងមួយសន្លឹកមួយសំនួរ ហើយបិទក្រដាសស្អិតនោះលើក្រដាសផ្ទាំងធំ។

# លំហាត់ជាក្រុម

## លំហាត់ទី ៩

បែងចែកប្រភេទនៃលក្ខណៈវិនិច្ឆ័យ៖

ចំណាយពេល ១៥នាទី ដើម្បី៖

ដាក់សំណួរ ឬលក្ខណៈវិនិច្ឆ័យ អោយបានចំនួនបួន ឬប្រាំប្រភេទ។

ដាក់ក្រដាសស្អិតតូចៗនៅផ្នែកខាងលើក្រដាសស្អិតធំជាង ដែលតំណាងឲ្យប្រភេទទូទៅចំនួនបួន ឬប្រាំ

# លំហាត់ជាក្រុម (លំហាត់ទី ១០)

**លក្ខណៈភ្នាក់ងារជីវសាស្ត្រ** (អត្រាឈឺ អត្រាស្លាប់ ការព្យាបាល និងការទប់ស្កាត់ ផ្លូវចម្លង ភាពឆ្លងទៅសហគមន៍  ភាពធនរបស់ភ្នាក់ងារ)

**មន្ទីរពិសោធន៍** (ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ឥដ្ឋ ជញ្ជាំង ទូរដាក់សម្ភារៈ តុធ្វើការពិសោធន៍ និងធាតុផ្សំដែលមានស្រាប់ដទៃទៀត ដែលបង្កអោយមានហានិភ័យ ដូចជា សត្វពាហនៈជាដើម)

**មនុស្ស**

**វិធានការកាត់បន្ថយ** (បួនប្រភេទ)

**បរិស្ថាន** (រួមទាំងសហគមន៍)

**ហិរញ្ញវត្ថុ**

# លំហាត់ជាក្រុម លំហាត់ទី ១១

សូមប្រើប្រាស់សេណារីយ៉ូស្តីពីជំងឺអេដស៍៖

ចាត់ប្រភេទសំណួរ ឬលក្ខណៈវិនិច្ឆ័យយោងទៅតាម៖ ភាវនីយភាព (ភាពដែលអាចកើតឡើង) និងផលវិបាក

តើលក្ខណៈវិនិច្ឆ័យណាខ្លះដែលមានសារៈសំខាន់ជាង លក្ខណៈវិនិច្ឆ័យដទៃទៀត?

សូមសរសេរចម្លើយនៅលើក្រដាសផ្ទាំងធំ

# ការសង្ខេបខ្លឹមសារ

តើលទ្ធផលនៃការវាយតម្លៃហានិភ័យរបស់អ្នកអាចមានការផ្លាស់ប្តូរយ៉ាងណាខ្លះ តាមរយៈការប្រើប្រាស់ដំណើរការនេះ (បើប្រៀបជាមួយវិធីសាស្ត្រពីមុនរបស់អ្នក)?

តើការវាយតម្លៃហានិភ័យរបស់អ្នកមានភាពប្រសើរឡើងយ៉ាងណាខ្លះ?

សូមគិតអំពីរបៀបដែលអ្នកប្រើប្រាស់ ដើម្បីវាយតម្លៃហានិភ័យស្តីពីកុមារអាយុពីរឆ្នាំនៅក្នុងផ្ទះបាយ និងរបៀបដែលអ្នកវាយតម្លៃលើសេណារីយ៉ូជំងឺអេដស៍កាលពីដំបូង។

ការសង្ខេបខ្លឹមសារ

# អត្ថប្រយោជន៍នៃការវាយតម្លៃហានិភ័យដ៏ហ្មត់ចត់

- សម្របសម្រួលឲ្យមានដំណើរការវាយតម្លៃហានិភ័យដែលអាចធ្វើសារឡើងវិញបាន/អាចបង្កើតឡើងវិញបាន/មានតម្លាភាព
- សម្របសម្រួលឲ្យមានការសម្រេចចិត្តលើការកាត់បន្ថយហានិភ័យ
- ផ្តល់ជាឯកសារ អំពីការគ្រប់គ្រងគុណភាព

តើមានអ្វីខ្លះដែលអាចនៅខ្វះចន្លោះ នៅក្នុងការវាយតម្លៃហានិភ័យបច្ចេកទេសនេះ?

តើអ្វីជា “ហានិភ័យដែលអាចទទួលយកបាន”?

# ការទទួលស្គាល់ហានិភ័យ

ហានិភ័យផ្នែកជីវសុវត្ថិភាពនៃការប៉ះពាល់ដោយផ្ទាល់ចំពោះបុគ្គលនៅក្នុងមន្ទីរពិសោធន៍ និងចំពោះសហគមន៍មានរបាយហានិភ័យស្មើគ្នា



# ការទទួលស្គាល់ហានិភ័យ

ហានិភ័យផ្នែកជីវសុវត្ថិភាពនៃការប៉ះពាល់ដោយផ្ទាល់ចំពោះបុគ្គលនៅក្នុងមន្ទីរពិសោធន៍ និងចំពោះសហគមន៍មានហានិភ័យផ្ទុយគ្នា (មន្ទីរពិសោធន៍មិនទទួលយកហានិភ័យ)



# ការទទួលស្គាល់ហានិភ័យ

ហានិភ័យផ្នែកជីវសុវត្ថិភាពនៃការប៉ះពាល់ដោយផ្ទាល់ចំពោះបុគ្គលនៅក្នុងមន្ទីរពិសោធន៍ និងចំពោះសហគមន៍ហានិភ័យទប់ទល់បាន (មន្ទីរពិសោធន៍ធន់ទ្រាំជាមួយហានិភ័យ)



# ការទទួលស្គាល់ហានិភ័យ

ហានិភ័យផ្នែកជីវសុវត្ថិភាពនៃការប៉ះពាល់ដោយផ្ទាល់ចំពោះបុគ្គលនៅក្នុងមន្ទីរពិសោធន៍និងចំពោះសហគមន៍ជម្រុញដោយផលវិបាក



# ការឆ្លុះបញ្ចាំងជាលក្ខណៈបុគ្គល

- តើមានអ្វីខ្លះដែលថ្មីសម្រាប់ថ្ងៃនេះ?
- តើគំនិតអ្វីខ្លះដែលអ្នកធ្លាប់មានពីមុនមក? តើគំនិតទាំងនោះមានអត្ថន័យយ៉ាងណាចំពោះអ្នក?
- តើអ្នកនឹងផ្លាស់ប្តូរអ្វីខ្លះពេលអ្នកត្រឡប់ទៅស្ថាប័នដើមរបស់អ្នកវិញ? ប្រសិនបើអ្នកចង់ សូមចែករំលែកគំនិតរបស់អ្នកជាមួយអ្នកទាំងអស់គ្នាក្នុងថ្នាក់ទាំងមូល

# ការកាត់បន្ថយជីវហានិភ័យ

**ការគ្រប់គ្រងផ្នែកវិស្វកម្ម៖** ការផ្លាស់ប្តូរជារូបវ័ន្តទៅលើស្ថានីយ៍ធ្វើការងារ ឧបករណ៍ សម្ភារៈ បរិក្ខារ ទីកន្លែងផលិត ឬទិដ្ឋភាពពាក់ព័ន្ធដទៃទៀតនៃបរិស្ថានធ្វើការងារ ដែលកាត់បន្ថយ ឬទប់ស្កាត់ការប៉ះពាល់ជាមួយប្រភពគ្រោះថ្នាក់

**ការគ្រប់គ្រងផ្នែករដ្ឋបាល៖** គោលនយោបាយ បទដ្ឋាន និងគោលការណ៍ណែនាំដែលត្រូវបានប្រើប្រាស់ ដើម្បីគ្រប់គ្រងហានិភ័យ

**ការអនុវត្ត និងនីតិវិធី៖** ដំណើរការ និងសកម្មភាពនានា ដែលត្រូវបានបង្ហាញក្នុងការអនុវត្តជាក់ស្តែង ថាមានប្រសិទ្ធភាពក្នុងការកាត់បន្ថយហានិភ័យ

**សម្ភារៈការពារខ្លួន៖** សម្ភារៈដែលប្រើប្រាស់ដោយអ្នកធ្វើការ ដើម្បីការពារទប់ទល់ពីប្រភពគ្រោះថ្នាក់ក្នុងមន្ទីរពិសោធន៍

# គុណសម្បត្តិ/គុណវិបត្តិ

| វិធានការគ្រប់គ្រង | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| វិស្វកម្ម | មានប្រសិទ្ធភាព លុបបំបាត់ប្រភពគ្រោះថ្នាក់ | ការចំណាយច្រើន<br>ភាពស្មុគស្មាញ |
| រដ្ឋបាល | គោលវិធីរបស់អ្នកមានសមត្ថកិច្ច | គោលវិធីដោយប្រយោល ឆ្លើយតបនឹងបញ្ហាចម្បងលើកត្តាមនុស្ស |
| ការអនុវត្ត និងនីតិវិធី | ផ្អែកលើ SOP (នីតិវិធីប្រតិបត្តស្តង់ដា) | ចាំបាច់ត្រូវមានការបណ្តុះបណ្តាល និងការអភិបាល |
| **សម្ភារៈការពារខ្លួន**(PPE) | ងាយស្រួលប្រើប្រាស់ មិនចំណាយច្រើន | មិនអាចលុបបំបាត់ប្រភពគ្រោះថ្នាក់ បើ PPE មិនដំណើរការ នោះការប៉ះពាល់ជាមួយប្រភពគ្រោះថ្នាក់អាចកើតមាន មិនមានលក្ខណៈងាយស្រួលធ្វើការ សមត្ថភាពមានកម្រិតកំណត់ |

# ឋានានុក្រមនៃការគ្រប់គ្រង (HOC)

លុបបំបាត់ ឬជំនួស

ការគ្រប់គ្រងផ្នែកវិស្វកម្ម

ការគ្រប់គ្រងផ្នែករដ្ឋបាល

ការអនុវត្ត និងនីតិវិធី

ឧបករណ៍ការពារបុគ្គល

**វិធីសាស្ត្រគ្រប់គ្រងនៅផ្នែកខាងលើនៃបញ្ជី ជាទូទៅមានប្រសិទ្ធភាពជាង និងមានភាពការពារខ្ពស់ជាងវិធីសាស្ត្រនៅខាងក្រោម**

# តើវិធានការណ៍កាត់បន្ថយគ្រោះថ្នាក់ណាខ្លះ ដែលជះឥទ្ធិពលខ្លាំងបំផុតលើផ្នែកណា នៃសមីការការវាយតម្លៃហានិភ័យ?

**ការជំនួស**

(ការប្រើប្រាស់សម្ភារៈខុសៗគ្នា)

ជះឥទ្ធិពលលើផ្នែកណានៃសមីការវាយតម្លៃហានិភ័យ?

**ការលុបបំបាត់**

(មិនធ្វើការងារដែលបានគ្រោងទុក)

តើមានអ្វីកើតឡើង ចំពោះហានិភ័យ?

# ការអនុវត្តវិធានការណ៍កាត់បន្ថយ

យកល្អ ជាដំបូង អ្នកគួរពិចារណាដើម្បីលុបបំបាត់ ឬជំនួស

ការរួមបញ្ចូលនៃវិធានការណ៍នៃការគ្រប់គ្រង គួរត្រូវបានប្រើប្រាស់ដោយផ្អែកលើប្រសិទ្ធភាពរបស់វា និងសមត្ថភាពរបស់អ្នកក្នុងការអនុវត្តវិធានការណ៍ទាំងអស់នោះ

“ហានិភ័យអាចទទួលយកបាន”

# ឥទ្ធិពល “Wow”

វិធីសាស្រ្តដ៏ម៉ត់ចត់ចំពោះការកាត់បន្ថយហានិភ័យ ផ្តល់ឲ្យអ្នកនូវលទ្ធភាពដើម្បី៖

- បង្ហាញពីភាពត្រឹមត្រូវក្នុងការសម្រេចចិត្ត
- វាយតម្លៃផលប៉ះពាល់នៃការសម្រេចចិត្តក្នុងការកាត់បន្ថយហានិភ័យមួយចំនួន
- ប្រៀបធៀបប្រសិទ្ធភាពចំណាយ នៃការសម្រេចចិត្តកាត់បន្ថយហានិភ័យមួយចំនួន

# ការគ្រប់គ្រងជីវហានិភ័យ

**ការគ្រប់គ្រងជីវហានិភ័យ =**
**ការវាយតម្លៃ, ការកាត់បន្ថយ, ការអនុវត្ត**

ការកំណត់អត្តសញ្ញាណហានិភ័យ
ការកំណត់អត្តសញ្ញាណគ្រោះថ្នាក់/
ការគម្រាមកំហែង
ការវាយតម្លៃភាវនីយភាព
ការវាយតម្លៃផលវិបាក

ការលុបបំបាត់ ឬការជំនួស
ការគ្រប់គ្រងផ្នែកវិស្វកម្ម
ការគ្រប់គ្រងផ្នែករដ្ឋបាល
ការអនុវត្ត និងនីតិវិធី
ឧបករណ៍ការពារបុគ្គល

# ការកំណត់អត្តសញ្ញាណជីវហានិភ័យ



# តើអ្វីជាការអនុវត្ត?

- ការអនុវត្ត គឺជាមធ្យោបាយ ដែលនរណាម្នាក់ បំពេញមុខងារណាមួយ ឬដំណើរការឧបករណ៍អ្វីមួយ
- ការអនុវត្ត គឺជាលទ្ធផលនៃកិច្ចខិតខំទាំងអស់របស់ក្រុមហ៊ុន ឬអង្គភាព
- ការអនុវត្ត ធ្វើអោយការគ្រប់គ្រងជីវហានិភ័យប្រសើឡើង៖ អ្នកដឹងថា ប្រព័ន្ធការងាររបស់អ្នកដំណើរការ និងមាននិរន្តភាព ហើយអ្នកក៏អាចដឹងថា ហានិភ័យនេះស្ថិតក្នុងកម្រិតគ្រប់គ្រងដែលអាចទទួលយកបាន

# ប្រព័ន្ធគ្រប់គ្រងជីវហានិភ័យ

**ការគ្រប់គ្រង៖** ដំណើរការ នីតិវិធី រចនាសម្ព័ន្ធ និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងជីវហានិភ័យ

**ការធានា៖**ដំណើរការជាប្រព័ន្ធក្នុងការពិនិត្យលើប្រព័ន្ធការងារតាមរយៈសវនកម្ម និងអធិការកិច្ច

**ការកែលម្អ៖** ការកំណត់ និងការសម្រេចបាននូវគោលដៅការគ្រប់គ្រងជីវហានិភ័យផ្អែកលើយោបល់ត្រឡប់ពីខាងក្នុង និងខាងក្រៅ

# ការគ្រប់គ្រងជីវហានិភ័យ

## ការគ្រប់គ្រងជីវហានិភ័យ =
## ការវាយតម្លៃ, ការកាត់បន្ថយ, ការអនុវត្ត

ការកំណត់អត្តសញ្ញាណហានិភ័យ
ការកំណត់អត្តសញ្ញាណប្រភពគ្រោះថ្នាក់/ការគម្រាមកំហែង
ការវាយតម្លៃភាវនីយភាព
ការវាយតម្លៃផលវិបាក

ការលុបបំបាត់ ឬការជំនួស
ការគ្រប់គ្រងផ្នែកវិស្វកម្ម
ការគ្រប់គ្រងផ្នែករដ្ឋបាល
ការអនុវត្ត និងនីតិវិធី
ឧបករណ៍ការពារបុគ្គល

ការគ្រប់គ្រង
ការធានា
ការកែលម្អ

# ការកំណត់អត្តសញ្ញាណជីវហានិភ័យ



# បទដ្ឋានការគ្រប់គ្រងជីវហានិភ័យមន្ទីរពិសោធន៍

- CWA 15793:2008
- ប្រព័ន្ធការគ្រប់គ្រង
- អនុលោមតាមបទដ្ឋានអន្តរជាតិដទៃទៀត ដូចជា ISO 9001/14001 និង OHSAS 18001
- ផ្អែកលើការអនុវត្ត
- ជាការស្ម័គ្រចិត្ត
- ផ្អែកលើ PDCA

# គោលវិធីជាប្រព័ន្ធ



# CWA 15793:2008

ឧទាហរណ៍អំពីប្រធានបទដែលបានគ្របដណ្តប់៖




- គោលនយោបាយការគ្រប់គ្រងជីវហានិភ័យ
- ការកំណត់រកភាពគ្រោះថ្នាក់ ការវាយតម្លៃហានិភ័យ និងការគ្រប់គ្រងហានិភ័យ
- តួនាទី ការទទួលខុសត្រូវ និងសមត្ថកិច្ច
- ការបណ្តុះបណ្តាល ការយល់ដឹង និងសមត្ថភាព
- ការគ្រប់គ្រងផ្នែកប្រតិបត្តិការ
- ការឆ្លើយតបក្នុងគ្រាអាសន្ន និងផែនការពារករណីមិនបានគ្រោងទុក
- ការពិនិត្យតាមដាន និងការគ្រប់គ្រងលើបញ្ជីសារពើភ័ណ្ឌ
- ការស៊ើបអង្កេតលើគ្រោះថ្នាក់ និងឧបទ្ទវហេតុ
- អធិការកិច្ច និងសវនកម្ម
- ការពិនិត្យឡើងវិញលើការគ្រប់គ្រងជីវហានិភ័យ

តើគំរូ “ផែនការ ធ្វើ ពិនិត្យ ធ្វើសកម្មភាព” (PDCA) ពាក់ព័ន្ធយ៉ាងដូចម្តេចជាមួយ គំរូ “ការវាយតម្លៃ ការកាត់បន្ថយ ការអនុវត្ត” (AMP)?

# AMP vs. PDCA

ការវាយតម្លៃ = ផែនការ ធ្វើ ពិនិត្យ ធ្វើសកម្មភាព

ការកាត់បន្ថយ = ផែនការ ធ្វើ ពិនិត្យ ធ្វើ
សកម្មភាព

ការអនុវត្ត = ផែនការ ធ្វើ ពិនិត្យ ធ្វើសកម្មភាព



# គោលវិធីជាប្រព័ន្ធ


Plan
ផែនការ
ធ្វើ
Do
AMP
ពិនិត្យ
Act
ធ្វើសកម្មភាព
http://ecmeurope.net/wp-content/uploads/2009/11/800
PDCA_Cycle_svg.png

# ការស្ទះបញ្ចាំងជាលក្ខណៈបុគ្គល

- តើ AMP អាចយកទៅអនុវត្តនៅក្នុងមន្ទីរពិសោធន៍របស់អ្នកផ្ទាល់ បានដោយរបៀបណា?
- តើអ្នកអាចកែលម្អការគ្រប់គ្រងជីវហានិភ័យនៅមន្ទីរពិសោធន៍របស់អ្នកសម្រាប់រយៈពេលខ្លី និង រយៈពេលវែងយ៉ាងដូចម្តេច?
- តើមានបញ្ហាប្រឈមអ្វីខ្លះក្នុងការអនុវត្ត AMP?
- តើអ្វីខ្លះជាអត្ថប្រយោជន៍នៃការអនុវត្ត AMP?
- សូមសរសេរចម្លើយរបស់អ្នកនៅលើក្រដាសមួយសន្លឹក អ្នកចែករំលែកចម្លើយរបស់អ្នកឲ្យអ្នកដទៃស្តាប់ (បើអាច)

# សង្ខេប

- **អត្ថប្រយោជន៍នៃការវាយតម្លៃហានិភ័យដ៏ម៉ត់ចត់**
  - សម្របសម្រួលដំណើរការវាយតម្លៃហានិភ័យ អាចធ្វើឡើងវិញបាន/អាចផលិតឡើងវិញបាន (repeatable/reproducible)
  - សម្របសម្រួលការសម្រេចចិត្តការកាត់បន្ថយហានិភ័យ
  - ផ្តល់ការចងក្រងឯកសារសម្រាប់ការគ្រប់គ្រងគុណភាព
- **ចំណាត់ប្រភេទទាំងបួននៃវិធានការណ៍ការគ្រប់គ្រងការកាត់បន្ថយហានិភ័យ**
  - ការគ្រប់គ្រងផ្នែកវិស្វកម្ម
  - ការគ្រប់គ្រងផ្នែករដ្ឋបាល
  - ការអនុវត្ត និងនីតិវិធី
  - ឧបករណ៍ការពារខ្លួន

# សង្ខេប

- **ការអនុវត្តការគ្រប់គ្រងការកាត់បន្ថយហានិភ័យ**
  - ជាដំបូងត្រូវពិចារណាយកការលុបបំបាត់ ឬការជំនួស
  - បន្សំនៃវិធានការការគ្រប់គ្រង គួរត្រូវបានប្រើប្រាស់ផ្អែកលើប្រសិទ្ធភាពរបស់វិធានការនោះ និងសមត្ថភាពរបស់អ្នកក្នុងការអនុវត្តវិធានការទាំងនោះ
  - គួរផ្អែកលើលទ្ធផលនៃការវាយតម្លៃហានិភ័យ ហើយត្រូវផ្តល់ឥទ្ធិពល “wow”

**តើការអនុវត្តអាចជួយធ្វើអោយប្រសើឡើងការគ្រប់គ្រងហានិភ័យដោយរបៀបណា?**

អ្នកដឹងថា ប្រព័ន្ធរបស់អ្នកដំណើរការបានល្អ និងមាននិរន្តភាព ហើយអ្នកដឹងថា ហានិភ័យណា ស្ថិតក្នុងកម្រិតដែលអាចទទួលយកបាន

ការកាត់បន្ថយគឺជាការធ្វើអោយប្រសើរឡើង និងរក្សានិរន្តភាព នៅពេលដែលវិធានការណ៍អនុវត្តត្រូវបានដាក់បញ្ចូល

# នៅចុងបញ្ចប់នៃម៉ូឌុលសិក្សានេះ
# អ្នកគួរតែមានសមត្ថភាពអាច៖

- ដឹងអំពីទស្សនាទានជាមូលដ្ឋាន និងពាក្យបច្ចេកទេសនៃការគ្រប់គ្រងជីវហានិភ័យ
- យល់អំពីគំរូ AMP សម្រាប់ការគ្រប់គ្រងជីវហានិភ័យ
- យល់អំពីអត្ថប្រយោជន៍នៃការអនុវត្តប្រព័ន្ធការគ្រប់គ្រងជីវហានិភ័យ ដើម្បីកាត់បន្ថយហានិភ័យពាក់ព័ន្ធជាមួយការចាត់ចែង ការស្តុកទុក និងការបោះចោលភ្នាក់ងារជីវសាស្ត្រ
- យល់អំពីតួនាទីរៀងខ្លួនរបស់អ្នកប្រតិបត្តិនានាដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងជីវហានិភ័យ